## ចាក់សោកៃកាំភ្លើង

**តើវាជាអ្វី៖**

មានសោពីរគន្លាក់ដែលអាចដាក់ពីលើ ស៊ុម កៃកាំភ្លើង ដើម្បីការពារកុំឱ្យកៃកាំភ្លើងត្រូវបានរបូតកៃ។

លេខកូដសម្ងាត់ ប៊ូតុងចុច ឬសោចាក់ ឧបករណ៍ដើម្បីរក្សាសុវត្ថិភាព។

**តម្លៃ៖**

$5 ដល់ $30 ឡើងទៅ



### គុណសម្បត្តិ

- តម្លៃសមរម្យ
- ទំហំតូច
- ងាយស្រួលប្រើ

### គុណវិបត្តិ

- មិនអាចការពារចោរលួចបាន
- មិនអាចប្រើការបានជាមួយនិង កាំភ្លើងទាំងអស់ទេ
- សោមានគុណភាពទាបអាចនឹង បែកបាក់

## មូលហេតុដែលអ្នកគួរតែ ចាក់សោកាំភ្លើងរបស់អ្នក



មានឧបករណ៍ជាច្រើនសម្រាប់យកមកចាក់សោ កាំភ្លើងរបស់អ្នក។ នៅពេលដែលកាំភ្លើងរបស់អ្នក មិនស្ថិតនៅជាប់និងខ្លួនរបស់អ្នក វានិងអាចត្រូវបានគេយកមកប្រើខុសច្បាប់។ **កូនក្មេងនិងមនុស្សដែលគ្មានសិទ្ធិអនុញ្ញាតមិនគួរដឹងអំពីលេខកូដសម្ងាត់ឬទីកន្លែងដែលអ្នកទុកកូនសោរទេ។**

### ចាក់សោវាដើម្បី៖

**ការពារកុំឱ្យគេលួចកាំភ្លើងរបស់អ្នក**

**ការពារកុំឱ្យកូនក្មេងរកឃើញ ហើយប្រើ កាំភ្លើងរបស់អ្នក**

**ការពារកុំឱ្យមានមនុស្សស្លាប់ដោយសារ ធ្វើអត្តឃាតក្នុងពេលមានវិបត្តិ**

**ការពារកុំឱ្យយកកាំភ្លើងទៅសាលារៀន**

LOCK IT UP

ងាយស្រួលប្រើ មានសុវត្ថិភាព
ប្រើបានភ្លាមៗ

**www.lockitup.org**

យើងតភ្ជាប់អ្នកជាមួយកន្លែងផ្ទុកឧបករណ៍ ដែល ការពារកុំអោយមានគ្រោះថ្នាក់ដោយសារកាំភ្លើង មានសុវត្ថភាពហើយអាចយកមកប្រើការបានភ្លាមៗ។

**អាចទិញឧបករណ៍សម្រាប់ចាក់សោ កាំភ្លើង នៅគ្រប់កន្លែងដែលមានលក់ កាំភ្លើង និងគ្រឿងបន្លាស់៖**

- ហាងលក់កាំភ្លើង
- ហាងលក់សម្ភារ:កីឡា
- ហាងលក់ទូដែក
- ហាងលក់ហាតវែរ
- តាមអនឡាញ

ដើម្បីទទួលបានការបញ្ចុះតម្លៃសម្រាប់ការទិញរបស់ផ្ទុកឧបករណ៍ សូមចូលទៅ ហាងលក់រាយណាមួយដែលជាដៃគូរបស់យើងហើយប្រាប់គេ អំពីកម្មវិធីនេះ។

Public Health
Seattle & King County

Khmer

# ឧបករណ៍ សម្រាប់ចាក់សោ កាំភ្លើង



តើមួយណាសមស្របសម្រាប់អ្នក?

LOCK IT UP

ងាយស្រួលប្រើ មានសុវត្ថិភាព
ប្រើបានភ្លាមៗ



## ឧបករណ៍សម្រាប់ចាក់សោកាំភ្លើង

មានឧបករណ៍ជាច្រើនដែលអាចយកមកប្រើសម្រាប់ចាក់សោ កាំភ្លើងរបស់អ្នក។ អ្នកជំនាញជាច្រើនណែនាំ អោយប្រើប្រអប់សម្រាប់ចាក់សោ ទូដែកឬទូសម្រាប់រក្សាទុកកាំភ្លើងដែលមានប៊ូតុងចុចលេខ មានលេខកូដសម្ងាត់ ឬទូចាក់សោមានផ្ទាំងចុចលេខ។

ការចាក់សោកាំភ្លើងគឺមានការ **ងាយស្រួលប្រើ**។ ទូសម្រាប់ផ្ទុកឧបករណ៍ដែលមានសុវត្ថិភាពមិនមែនទាល់តែថ្លៃឬពិបាកប្រើនោះទេ ហើយមានលក់នៅក្នុង ហាងនិងតាមអនឡាញ។

កាំភ្លើងដែលជាប់សោគឺធ្វើអោយ**មានសុវត្ថិភាព**។ កាំភ្លើងរបស់អ្នកដែលជាប់សោគឺពិបាកឬមិនអាចឱ្យ ចោរលួចយកបាន។ ហើយអ្នកអាចការពារក្មេងចង់ដឹងចង់ស្គាល់ និងមនុស្សមានវិបត្តិកុំឱ្យបង្ករបួសខ្លួនឯងឬអ្នកដទៃ។

កាំភ្លើងជាប់សោគឺអាច**ប្រើបានភ្លាមៗ**។ អ្នកអាចបើក ប្រអប់ចាក់សោ ឬឧបករណ៍ផ្ទុកផ្សេងទៀត យ៉ាងលឿនក្នុងពេលមានអាសន្ន។

## ប្រអប់ចាក់សោ

### តើវាជាអ្វី៖

ទូដែកខ្នាតតូចសម្រាប់រក្សាទុកកាំភ្លើងខ្លីប្រកបដោយសុវត្ថិភាព។ ភាគច្រើនគេអាចចាប់ជាប់ទៅនិងប៉ូឡូង ឬ ប្រើខ្សែកាបការពារ។

បើកដោយប្រើលេខកូដសម្ងាត់ ផ្ទាំងចុចលេខឌីជីថល ការសម្គាល់ស្នាមក្រយ៉ៅដៃ ឬកូនសោ។

### តម្លៃ៖

$25 ដល់ជាង $200



### គុណសម្បត្តិ

- ☑ តម្លៃសមរម្យ
- ☑ អាចការពារចោរលួច
- ☑ ទំហំតូច
- ☑ ងាយស្រួលប្រើ

### គុណវិបត្តិ

- តម្លៃខ្ពស់ជាងជម្រើសមួយចំនួន

## ទូដាក់កាំភ្លើងឬទូដែក

### តើវាជាអ្វី៖

ទូដែកខ្នាតធំសម្រាប់រក្សាទុកកាំភ្លើងវែង កាំភ្លើងខ្លី ឬវត្ថុមានតម្លៃ។

បើកដោយប្រើលេខកូដសម្ងាត់ ផ្ទាំងចុចលេខ តាមរយៈការស្គាល់ស្នាមក្រយៅម្រាមដៃ ឬកូនសោ។

### តម្លៃ៖

$150 ដល់ រាប់ពាន់ដុល្លារ



### គុណសម្បត្តិ

- ☑ ប្រើបានច្រើនយ៉ាង
- ☑ អាចការពារចោរលួច
- ☑ ទំហំធំ
- ☑ ធន់

### គុណវិបត្តិ

- ធ្ងន់និងពិបាករំកិល
- មានតម្លៃខ្ពស់ជាងជម្រើសមួយចំនួន

## សោខ្សែកាប

### តើវាជាអ្វី៖

ឧបករណ៍ដែលទប់ស្កាត់ថតខាងក្នុង កុំឱ្យកាំភ្លើងបាញ់ចេញ។ អាចស៊កខ្សែកាបចូល ឬតាម ប្រឡោះដាក់បង់កាំភ្លើង ថតខាងក្នុង ឬ បារ៉ែលកាំភ្លើង ដើម្បីរាំងខ្ទប់គ្រាប់កាំភ្លើង កុំឱ្យចូលកន្លែងត្រៀមបាញ់។

លេខកូដសម្ងាត់ ឬកូនសោអាចដោះសោបាន។

### តម្លៃ៖

ឥតគិតថ្លៃ ដល់ $20 ឡើងទៅ



### គុណសម្បត្តិ

- ☑ ឥតគិតថ្លៃ ឬតម្លៃសមរម្យ
- ☑ ប្រើបានច្រើនឧបករណ៍

### គុណវិបត្តិ

- មិនអាចការពារចោរលួច
- ខ្សែកាបខ្លះអាចកាត់បាន
- មិនមែនអាចប្រើបានជាមួយនិងកាំភ្លើងទាំងអស់ទេ